ព្រះរាជាណាចក្រកម្ពុជា
*Kingdom of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ
*Nation Religion King*

ទីស្តីការគណៈរដ្ឋមន្ត្រី
*Office of the Council of Ministers*
លេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល
*Secretariat of the Task Force*

## សេចក្តីប្រកាសពត៌មាន

# ការផ្តល់ថវិកានៅថ្ងៃសិទ្ធិមនុស្ស ពីប្រទេសអូស្ត្រាលីសំរាប់កម្មវិធីផ្សព្វផ្សាយសម្រាប់សាលាក្តីខ្មែរក្រហម

ដើម្បីកត់សំគាល់នូវថ្ងៃសិទ្ធិមនុស្ស ទី១០ ធ្នូ ២០០៥ រដ្ឋាភិបាលអូស្ត្រាលីបានប្រកាសនូវការផ្តល់ថវិកាចំនួន ៣៦,០០០ដុល្លារសហរដ្ឋអាមេរិក (៤៨៣០៦ដុល្លារអូស្ត្រាលី) សំរាប់លេខាធិការដ្ឋាននៃក្រុមការងាររាជរដ្ឋាភិបាលសំរាប់ជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ដើម្បីដំណើរការវេទិកាផ្សព្វផ្សាយតំបន់ នៅតាមបណ្តាទីរួមខេត្តទូទាំងប្រទេស ។

ការផ្តល់ថវិកានេះនឹងធ្វើអោយមានវេទិកាពត៌មាន ដែលនឹងត្រូវរៀបចំរាល់ទីរួមខេត្តក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងកំឡុងឆមាសទី១ នៃឆ្នាំ២០០៦ ។ ប្រជាជនកម្ពុជានៅតាមជនបទ នឹងទទួលនូវពត៌មានដែលគួរអោយទុកចិត្តបានអំពីលក្ខណៈ និងទំរង់នៃសាលាក្តីខ្មែរក្រហមដែលនឹងត្រូវបង្កើតក្នុងពេលឆាប់ៗនេះ តាមរយៈកិច្ចប្រជុំជាសាធារណៈ ខិតប័ណ្ណផ្សព្វផ្សាយពត៌មាន និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយកាសែត វិទ្យុ និងទូរទស្សន៍ ។ វេទិកាផ្សព្វផ្សាយតំបន់នេះនឹងបន្តនូវសកម្មភាពដែលត្រូវបានធ្វើដោយក្រុមការងាររាជរដ្ឋាភិបាលរួចហើយដូចជា សន្និសីទសារពត៌មាន ការសម្ភាសន៍តាមរយៈវិទ្យុ ទូរទស្សន៍ និងការបោះពុម្ពនិងផ្សព្វផ្សាយនូវកូនសៀវភៅស្តីពី "ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម" ដែលត្រូវបានបោះពុម្ពលើកទី១ ចំនួន ១៥,០០០ក្បាល ក៏ដូចជាការបង្កើតនូវគេហទំព័ររបស់ក្រុមការងាររាជរដ្ឋាភិបាល www.cambodia.gov.kh/krt/ ។

ការផ្តល់ថវិកាចុងក្រោយនេះ ជាផ្នែកមួយនៃកម្មវិធីផ្តល់ថវិកាទ្រង់ទ្រាយតូចសំរាប់គាំទ្រសិទ្ធិមនុស្ស ២០០៥-២០០៦ និងជាការបន្តជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលីសំរាប់កិច្ចការរៀបចំសំរាប់សាលាក្តីខ្មែរក្រហម ។ ថវិកាចំនួន១៩៩៦០ ដុល្លារសហរដ្ឋអាមេរិកត្រូវបានផ្តល់ក្នុងខែតុលា ក្រោមមូលនិធិសិទ្ធិមនុស្សនិងអភិបាលកិច្ចរបស់ស្ថានទូតអូស្ត្រាលីសំរាប់បោះពុម្ពជាថ្មី និងការបែងចែកអោយបានទំលំទូលាយជាងមុននូវកូនសៀវភៅដ៏ពេញនិយមរបស់លេខាធិការដ្ឋានដែលត្រូវបានបោះពុម្ពក្នុងឆ្នាំ២០០៤ ជាមួយជំនួយពីទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ ។

ថ្ងៃទី ១៤ ធ្នូ ២០០៥

*សំរាប់ពត៌មានបន្ថែម សូមទាក់ទងលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលកម្ពុជា (០២៣) ៤២៨ ៩៥២ ឬ បណ្ឌិត ហេឡិន ចារិស (០១២) ៨១២ ៦៥៨*